ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សារលិខិតជូនពរ

## សូមគោរពជូន
## សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!**

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំសកល ឆ្នាំ២០២៣ ខាងមុខនេះ ខ្ញុំបាទនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមលើកហត្ថប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា ប្រោះព្រំ ប្រទានពរជ័យ សិរីសួស្តី បវរមហាប្រសើរជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

ឆ្លៀតក្នុងឱកាសដ៏សោមនស្សរីករាយនេះដែរ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវមនោសញ្ចេតនាគោរព និងដឹងគុណដោយស្មោះអស់ពីដួងចិត្តចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ចំពោះវីរភាពដ៏ឧត្តុង្គឧត្តម និងថ្លៃថ្លាបំផុតចំពោះជាតិមាតុភូមិកម្ពុជា ដែលជានិច្ចកាល **សម្តេច** បានយកអស់កម្លាំងកាយចិត្ត ពុះពារ លះបង់ ប្រឹងប្រែងក្នុងការជួយដោះស្រាយទុក្ខលំបាករបស់ប្រជាជនគ្រប់កាលៈទេសៈ តាមរយៈចលនាកាកបាទក្រហមកម្ពុជា ហើយរាល់សកម្មភាពទាំងនេះបានបង្ហាញឱ្យឃើញយ៉ាងប្រត្យក្សនូវគំរូវីរភាពជាស្ត្រីឆ្នើមមួយរូបរបស់ប្រទេសជាតិ ព្រមទាំងជាភរិយា និងជាមាតាដ៏ប្រសើរឧត្តម។

ជាថ្មីម្តងទៀត ក្នុងឱកាសដ៏មហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកសូមប្រោសប្រទានពរជ័យជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងសមប្រកបនូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជា** មេត្តាទទួលនូវគារវភាពដ៏ខ្ពង់ខ្ពស់ និងជ្រាលជ្រៅបំផុតពីយើងខ្ញុំទាំងអស់គ្នា។៚

ថ្ងៃ ចន្ទ ១១ រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ហ៊ុន សុខា

ផ្លូវវិថីអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh